**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៥
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា
ភាសាដើម : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Feb-2015, 09:24
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:
ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:
ឈ្មោះមន្ត្រីដែលបានពិនិត្យ:
ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ នួន ជា ឲ្យទទួលយកឯកសារ ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
ជនជាប់ចោទ
នួន ជា
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

# ចម្លើយតប

1. សហព្រះរាជអាជ្ញា សូមធ្វើការឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា ដែលបានដាក់អនុលោមតាមវិធាន៨៧(៤) ("មេធាវីការពារក្តី") សុំឱ្យទទួលយកឯកសារថ្មីៗ ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី[1]។ សហព្រះរាជអាជ្ញាមិនជំទាស់នឹងការទទួលយកឯកសារទាំងនេះឡើយដែលអាចនាំដល់ការស្វែងរកការពិត ហើយដែលនឹងជួយដល់អង្គជំនុំជម្រះសាលាដំបូង ទោះបីមានការខកខានរបស់មេធាវីការពារក្តី ក្នុងការបំពេញលក្ខខណ្ឌដែលមានចែងយ៉ាងច្បាស់នៅក្រោមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងក៏ដោយ។ ក៏ប៉ុន្តែ ឯកសារដែលបានស្នើឡើងដោយមេធាវីការពារក្តី រួមទាំងសៀវភៅមួយក្បាលដែលមួយផ្នែកនៃសៀវភៅនេះ និងឯកសារមួយចំនួនទៀតគឺផ្អែកទៅលើមួយផ្នែកនៃសៀវភៅនោះដែលមិនពិត។ លើសពីនេះ សហព្រះរាជអាជ្ញាសូមជំទាស់នឹងនីតិវិធីដែលមេធាវីការពារក្តី នួន ជា បានលាក់កំបាំងចំពោះភស្តុតាងនេះ និងការខកខានដោយចេតនាមិនបានគោរពតាមវិធាននានារបស់តុលាការ ក្នុងការជូនដំណឹងជាមុនអំពីឯកសារ មកអង្គជំនុំជម្រះសាលាដំបូង និងភាគីផ្សេងទៀត ពីចេតនារបស់ខ្លួនក្នុងការប្រើប្រាស់ឯកសារនោះទាក់ទងនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

2. ទាក់ទងនឹងឯកសារប្រាំដែលបានស្នើដោយមេធាវីការពារក្តី សហព្រះរាជអាជ្ញាមិនជំទាស់នឹងការទទួលយកអត្ថបទកាសែតភ្នំពេញប៉ុស្តិ៍ ចុះខែឧសភា ឆ្នាំ២០១៣ ដែលមានបទសម្ភាសន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី[2]ទេ។ ប៉ុន្តែ សហព្រះរាជអាជ្ញាបានសង្កេតឃើញថា មេធាវីការពារក្តី នួន ជា បានលើកយកខ្លឹមសារនៃអត្ថបទសារព័ត៌មាននេះធ្វើឱ្យមានការយល់ច្រឡំ ក្នុងអំឡុងនៃការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដោយអះអាងថា អ៊ុំ សុផានី បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា គាត់បានរៀបការដោយបង្ខំ[3]។ ក្នុងអត្ថបទកាសែតភ្នំពេញប៉ុស្តិ៍ នៅត្រង់វាក្យខណ្ឌមួយដែលមានគូសរង្វង់បញ្ជាក់យ៉ាងច្បាស់ គឺជាបទសម្ភាសន៍របស់អ្នកយកព័ត៌មានជាមួយ អ៊ុំ សុផានី។ ក្នុងវាក្យខណ្ឌនេះ កំណត់ហេតុដែលទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីអាពាហ៍ពិពាហ៍របស់គាត់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺស៊ីសង្វាក់គ្នានឹងសក្ខីកម្មរបស់គាត់[4]។ តាមពិតគឺអ្នកកាសែតមិនមែនអ្នកស្រី អ៊ុំ សុផានី ទេ ដែលជាអ្នកកំណត់អាពាហ៍ពិពាហ៍របស់នាង ថា "បង្ខំ" នៅក្នុងអត្ថបទកាសែតនោះ។

---

[1] **E337** សំណើតាមវិធាន ៨៧(៤) របស់ នួន ជា ស្នើសុំឱ្យទទួលយកឯកសារទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី, ២៨ មករា ២០១៥។

[2] *ឯកសារ ៤,* ENG 01058320។

[3] **E1/252.1** ប្រតិចារឹក, ២៦ មករា ២០១៥, 09.24.28។

[4] *ឯកសារ ៤,* ENG 01058320: "ខ្ញុំស្រឡាញ់ប្តីខ្ញុំ។ យើងជាផ្នែកនៃ 'ការប្តេជ្ញាចិត្ត' និងបានរៀបការនៅចំពោះមុខអង្គការ។ យើងធ្លាប់ជាមិត្តរួមថ្នាក់ជាមួយគ្នា ហើយខ្ញុំទៅតាមគាត់ទៅស្រុកកំណើតរបស់គាត់"។

3. ត្រង់នេះហើយដែលបញ្ជាក់ពីមូលហេតុដែលមេធាវីការពារក្តី នួន ជា មិនអាចត្រូវបានអនុញ្ញាតឲ្យសួរដេញដោលសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗ ពីឯកសារថ្មីៗដែលគាត់បានលាក់កំបាំងដោយចេតនា និងខកខានមិនបានផ្តល់ការជូនដំណឹងជាមុន តាមរយៈសំណើដែលបានដាក់ ដោយអនុលោមតាមវិធាន៨៧(៤) នៅមុនពេលនៃការផ្តល់សក្ខីកម្មរបស់បុគ្គលរូបនោះ។ ការសួរដេញដោលបែបនេះ មិននាំដល់ការស្វែងរកការពិតឡើយ ដោយហេតុថា សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលកំពុងផ្តល់សក្ខីកម្ម អង្គជំនុំជម្រះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាសុទ្ធតែត្រូវបានរារាំងមិនឲ្យមានឯកសារពិតចំពោះមុខពួកគាត់ ដែលនេះជាមូលដ្ឋាននៃការសួរដេញដោលរបស់មេធាវីការពារក្តី។ តាមពិត ឯកសារនេះ និងមិនមែនការកំណត់ចរិកលក្ខណៈរបស់មេធាវីការពារក្តីចំពោះឯកសារនេះទេ នោះភ័ស្តុតាងដ៏ល្អបំផុត និងដែលអង្គជំនុំជម្រះគប្បីពឹងផ្អែក។ តាមរយៈការលាក់កំបាំងឯកសារនេះ និងការដែលពួកគេមិនបានធ្វើឲ្យឯកសារនេះ ជាផ្នែកនៃកំណត់ហេតុក្នុងពេលសួរដេញដោលរបស់គាត់ មេធាវីការពារក្តីមានលទ្ធភាពទាញយកខ្លឹមសារនៃឯកសារទាំងនោះធ្វើឲ្យសាក្សី អង្គជំនុំជម្រះ និងសាធារណជន មានការយល់ខុស។

4. សហមេធាវីការពារក្តីអន្តរជាតិរបស់ នួន ជា ក៏ធ្លាប់បានចូលរួមនៅក្នុងកលល្បិចដូចគ្នានេះ ជាមួយសាក្សី កែវ ចាន់ដារ៉ា ទាក់ទងនឹងអត្ថបទមួយដែលបានចុះផ្សាយនៅក្នុងទស្សនាវដ្តី *ស្វែងរកការពិត* របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)។ ក្នុងអំឡុងនៃការសួរដេញដោលនោះ មេធាវីការពារក្តីបានសួរសាក្សីថាតើគាត់ជាអ្នកសរសេរអត្ថបទនោះសម្រាប់ទស្សនាវដ្តីនោះមែនឬទេ និងបានឲ្យដឹងថា សាក្សីកុហកនៅពេលសាក្សីបដិសេធថា គាត់មិនបានសរសេរអត្ថបទណាមួយនោះ[5]។ បើសិនមេធាវីការពារក្តី នួន ជា បានបង្ហាញអត្ថបទនោះជាមុនដល់សាក្សីរូបនេះ ភាគី និងអង្គជំនុំជម្រះ ដូចដែលវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក តម្រូវ ម្ល៉េះសមយើងបានរកឃើញថា អត្ថបទដែលកំពុងចោទជាសំណួរនេះ ការពិត មិនមែនសរសេរឡើងដោយ កែវ ចាន់ដារ៉ា ទេ ប៉ុន្តែផ្ទុយទៅវិញ វាជាវាក្យខណ្ឌមួយនៃសៀវភៅមួយក្បាលដែលអ្នកនិពន្ធឈ្មោះ ឆាយ ចាន់ដា បានពឹងផ្អែកលើបទសម្ភាសន៍មួយរបស់សាក្សីរូបនេះតែប៉ុណ្ណោះ[6]។

---

[5] សេចក្តីព្រាងប្រតិចារឹក, ២ កុម្ភៈ ២០១៥, 15.53.10។

[6] មេធាវីការពារក្តី នួន ជា បានជូនយោបល់តាមសារអេឡិចត្រូនិចនៅចុងថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ថា ខ្លួនមានបំណងដាក់សំណើមួយស្របតាមវិធាន៨៧(៤) សុំឲ្យទទួលយកអត្ថបទនេះ ប៉ុន្តែមកទល់ពេលនេះបានខកខានជារហូតមក។ ទាក់ទងនឹងបញ្ហារបស់មេធាវីការពារក្តីអំពីការកំណត់ចរិកលក្ខណៈមិនត្រឹមត្រូវថាឯកសារនេះជាអត្ថបទដែលបានសរសេរដោយសាក្សីរូបនេះ សហព្រះរាជអាជ្ញាសូមដាក់ជូនសំណៅចម្លងមួយច្បាប់នៃឯកសារនេះដោយភ្ជាប់ទៅជាមួយជា **ឧបសម្ព័ន្ធ ១**។ ការសន្និដ្ឋានចុងបញ្ចប់នៃអត្ថបទនេះ មានកំណត់ហេតុដូចតទៅ៖ 'ក្រុម *ស្វែងរកការពិត* សូមអរគុណលោក ឆាយ ចាន់ដា អ្នកនិពន្ធសៀវភៅ

5. តាមរយៈការគេចវេសពីវិធាននានារបស់តុលាការ ដែលតម្រូវឱ្យមានការជូនដំណឹងជាមុន ពីឯកសារដែលភាគីមានបំណងពឹងផ្អែក មេធាវីការពារក្តី នួន ជា បានចូលរួមក្នុងទម្រង់នៃអំពើប្រព្រឹត្តមិនត្រឹមត្រូវដោយមានការត្រិះរិះ និងដឹងទុកជាមុន ដែលជាគ្រោះថ្នាក់ដល់ការស្វែងរកការពិត និងគប្បីត្រូវបានច្រានចោលជាមុននៅក្រោមវិធាន៨៧។ ទាក់ទងនឹងឯកសារបីទៀត ដែលពាក់ព័ន្ធនឹង អ៊ុំ សុផានី មេធាវីការពារក្តីបានទទួលស្គាល់ថា ខ្លួនបានទទួលឯកសារទាំងនោះ "នៅចុងខែវិច្ឆិកា ឆ្នាំ២០១៤ ក្នុងពេលត្រៀមសម្រាប់សក្ខីកម្មរបស់អ្នកស្រី អ៊ុំ សុផានី"[7]។ ម្យ៉ាងទៀតថាអស់រយៈពេលជិតពីរខែ ដែលមេធាវីការពារក្តីបានលាក់កំបាំងឯកសារនេះ ពីអង្គជំនុំជម្រះ និងភាគីដទៃទៀត អំពីចេតនារបស់ខ្លួនក្នុងការប្រើប្រាស់ឯកសារនេះ ក្នុងពេលផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យច្រានចោលមេធាវីការពារក្តីជាមុនមិន ឱ្យសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងពេលអនាគតដែលផ្អែកលើឯកសារនានាដែលមេធាវីការពារក្តីបានលាក់កំបាំងដោយចេតនា និងខកខានមិនបានជូនដំណឹងដល់អង្គជំនុំជម្រះ និងភាគីដទៃទៀត។

6. ទាក់ទងនឹងឯកសារបួនផ្សេងទៀតដែលបានស្នើឱ្យទទួលយកដោយមេធាវីការពារក្តី សហព្រះរាជអាជ្ញាសន្និដ្ឋានថា សៀវភៅមានចំណងជើងថា *Under the Drops of Falling Rain (នៅក្រោមដំណក់ទឹកភ្លៀង)(ឯកសារ១)* និងការពិនិត្យឡើងវិញទៅលើសៀវភៅនេះ ដែលបានផ្សព្វផ្សាយនៅលើគេហទំព័រអ៊ិនធ័រណិតមួយឈ្មោះថា *The Modern Novel(ប្រលោមលោកទំនើប)*(ឯកសារ៥) មិនមានអង្គសេចក្តីដែលអាចឱ្យទទួលយកបានស្របតាមវិធាន៨៧ ទេ។ នៅពេលសួរអំពីសៀវភៅនេះ នៅក្នុងសវនាការ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា សៀវភៅនេះគ្រាន់តែជាផ្នែកមួយនៃ "រឿងពិត" ដែលបានលើកឡើងតែប៉ុណ្ណោះ ប៉ុន្តែក៏មាន "ព័ត៌មានផ្សេងទៀត" ដែល "ច្របល់បញ្ចូលគ្នា" ជាមួយនឹងរឿងពិតទាំងនោះ និងថា"ចរិកលក្ខណៈទាំងប៉ុន្មាន" ត្រូវបានបង្កើតឡើងសម្រាប់រឿងប្រលោមលោក[8]។ ការពិនិត្យសៀវភៅនេះឡើងវិញ ដែលបានដាក់ដោយមេធាវីការពារក្តី ជាឯកសារ៥ ឃើញថាមាន "ការប្រឌិតខ្លះៗ"[9] មែន។ សហព្រះរាជអាជ្ញាសន្និដ្ឋានថាពិតជាគ្មានតម្លៃចំពោះការចំណាយពេលធំដុំណាមួយចាំបាច់សម្រាប់បញ្ជាក់ថា តើផ្នែកណាខ្លះនៃសៀវភៅ *Under the Drops of Falling Rain* នេះ គឺជារឿងប្រឌិត និងផ្នែកណាជារឿងពិត

---

*War and Genocide: A Never-Ending Cycle of Human Brutality* ចំពោះការអនុញ្ញាតឱ្យយើងខ្ញុំផ្សព្វផ្សាយសាច់រឿងរបស់ សុក យ៉ាវ (Sok Yav) [ហៅ កែវ ចាន់ដារ៉ា] នៅក្នុងទស្សនាវដ្តីនេះ"។

[7] **E337** សំណើតាមវិធាន ៨៧(៤) របស់ នួន ជា ស្នើសុំឱ្យទទួលយកឯកសារទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី, ២៨ មករា ២០១៥, កថាខណ្ឌ៨។

[8] **E1/251.1** ប្រតិចារិកសវនាការ, ២៣ មករា ២០១៥, 15.16.48 ដល់ 15.19.16។

[9] *ឯកសារ ៥,* ត្រង់ ENG 01058321។

ជាពិសេស ចំពោះការពិតថា ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានដាក់បញ្ចូលកំណត់ត្រាប្រចាំថ្ងៃដើមរបស់នាង[10] និងសៀវភៅមួយក្បាលមានចំណងជើថា *When Will We Ever Meet Again (ពេលណាយើងជួបគ្នាទៀត)* ជាភ័ស្តុតាង មិនមែនជារឿងប្រឌិតឡើយ[11]។ ឯកសារដូចបានពោលខាងលើនេះ បានបំពេញបទដ្ឋាននៃភាពជឿជាក់ដែលជាលក្ខខណ្ឌតម្រូវ សម្រាប់ការទទួលយកជាភ័ស្តុតាង។ សៀវភៅដែលផ្នែកខ្លះមានរឿងប្រឌិត តែងមានហានិភ័យនៃការបង្កឲ្យមានភាពច្របូកច្របល់ វៀរលែងតែកិច្ចខិតខំប្រឹងប្រែងមួយត្រូវបានធ្វើឡើង ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការពិតថាតើ ផ្នែកណាជាផ្នែកប្រឌិត និងផ្នែកណាមិនមែនប្រឌិត។ សហព្រះរាជអាជ្ញាក៏សង្កេតឃើញផងដែរថា អ្វីដែលបានដាក់ដោយមេធាវីការពារក្ដីថាជា "ឯកសារ១" មិនមែនជាសំណៅចម្លងពិតនៃសៀវភៅ *Under the Drops of Falling Rain* ទេ ប៉ុន្តែគឺជាសំណុំអត្ថបទមួយដែលមានតែពីរបីទំព័រប៉ុណ្ណោះ ហើយដែលឧប្បត្តិដ្ឋាន និងភាពពិតរបស់វា មិនមាននរណាដឹងឡើយ។

7. ទាក់ទងនឹងសេចក្ដីប្រកាសព័ត៌មានរបស់សមាគមជនរងគ្រោះខ្មែរក្រហម(ឯកសារ២) និងការផ្សព្វផ្សាយតាមវិទ្យុជាតិនៃសេចក្ដីប្រកាសព័ត៌មាននេះ(ឯកសារ៣) សហព្រះរាជអាជ្ញាសង្កេតឃើញថា សេចក្ដីប្រកាសព័ត៌មាននេះ គឺចេញជាភាសាអង់គ្លេសតែមួយប៉ុណ្ណោះ ដោយបុគ្គលម្នាក់ដែលបានប្រើសម្រង់ផ្នែកប្រឌិតចេញពីសៀវភៅ *Under the Drops of Falling Rain*។ ដោយសារអ្វីៗត្រូវបានសរសេរ និងចេញផ្សាយជាភាសាអង់គ្លេស គ្មានភ័ស្តុតាងណាអាចបញ្ជាក់បានថា សេចក្ដីប្រកាសព័ត៌មាននេះ ត្រូវបានត្រួតពិនិត្យដោយដើមបណ្ដឹងរដ្ឋប្បវេណីឡើយ។ លើសពីនេះ ដោយហេតុថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនដែលបញ្ជូនផ្នែកស្ដីពីអាពាហ៍ពិពាហ៍ដោយបង្ខំប្រឌិតនេះដែលបានលើកមកពិភាក្សា ចូលក្នុងសៀវភៅនោះដែលមួយផ្នែកធ្វើជាភ័ស្តុតាងរបស់នាងនៅចំពោះមុខតុលាការ ដូច្នេះឯកសារទាំងនេះមិនអាចបង្កួចបង្អាប់ចំពោះសក្ខីកម្មរបស់នាង ឬមិនធ្វើឲ្យមានតម្លៃណាមួយនៃការស្វែងរកការពិតបានឡើយ។ មិនមែនជាផលប្រយោជន៍សម្រាប់សវនាការត្រឹមត្រូវយុត្តិធម៌ និងឆាប់រហ័សទេ ដែលអនុញ្ញាតឲ្យមានការសួរបង្កួចបង្អាប់ ដោយប្រើកំណត់ហេតុស្ដាប់ចម្លើយពីមុនរបស់សាក្សីម្នាក់ ដែលកំណត់ហេតុនេះមិនមែនជាផ្នែកមួយនៃសក្ខីកម្ម សម្រាប់តុលាការ។

8. ជាចុងក្រោយ ទាក់ទងនឹងការបដិសេធដែលមានការត្រិះរិះជាមុនរបស់មេធាវីការពារក្ដី នួន ជា មិនអនុវត្តតាមវិធាននានារបស់តុលាការ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី មិនគួរត្រូវបានកោះហៅឡើងវិញ និងមិនដាក់ឲ្យស្ថិតក្រោមការសួរដេញដោលបន្ថែមពីឯកសារទាំងនេះឡើយ។ មេធាវីការពារក្ដីមានឱកាសអនុវត្តតាមវិធានរបស់តុលាការ និងសួរដើម

[10] **E323.1.1** សៀវភៅកំណត់ត្រាប្រចាំថ្ងៃរបស់ អ៊ុំ សុផានី។

[11] **D22/3248** សៀវភៅ មានចំណងជើងថា "When Will We Ever Meet Again," *(ពេលណាយើងជួបគ្នាទៀត)* KHM 00562753-947; **E1/250.1** ប្រតិចារឹកសវនាការ, ២២ មករា ២០១៥, 13.50.45 ដល់ 13.51.47។

បណ្តឹងរដ្ឋប្បវេណីរូបនេះ អំពីបញ្ហាទាំងអស់នេះនៅក្នុងអំឡុងនៃការផ្តល់សក្ខីកម្មលើកដំបូងរបស់គាត់ ដោយគ្រាន់តែដាក់សំណើមួយឱ្យទាន់ពេលវេលា ស្របតាមវិធាន៨៧(៤) ជាការស្រេច។ មេធាវីការពារក្តី នួន ជា មិនគួរត្រូវបានលើកទឹកចិត្តចំពោះការបដិសេធ ដោយចេតនាចំពោះការមិនអនុវត្តតាមវិធាននានារបស់តុលាការ តាមរយៈការផ្តល់នូវឱកាសមួយផ្សេងទៀត ឱ្យសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះឡើយ។

9. ដោយហេតុថា បញ្ហាទាំងនេះជាប់ទាក់ទងនឹងការប្រើប្រាស់ឯកសាររបស់មេធាវីការពារក្តី ដែលជាបញ្ហាមួយមានសារៈសំខាន់ ដែលអាចប៉ះពាល់ដល់ការសួរដេញដោលសាក្សីក្នុងសប្តាហ៍នេះ សហព្រះរាជអាជ្ញាសូមស្នើការអនុញ្ញាតដាក់សេចក្តីសន្និដ្ឋាននេះជាភាសាអង់គ្លេសជាមុនសិន ចំណែកច្បាប់បកប្រែជាភាសាខ្មែរ នឹងដាក់តាមក្រោយក្នុងពេលឆាប់ៗនេះ។

10. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះ ៖

ក. ទទួលយកអត្ថបទកាសែតភ្នំពេញប៉ុស្តិ៍ ចុះខែឧសភា ឆ្នាំ២០១៣ (ឯកសារ ៤ ដែលបានស្នើឡើង) ប៉ុន្តែ សុំឱ្យបដិសេធសំណើសុំអនុលោមតាមវិធាន៨៧(៤) ទាក់ទងនឹងឯកសារបួនផ្សេងទៀតដែលបានស្នើឡើង, និង

ខ. ប្រាមចោលមិនឱ្យមេធាវីការពារក្តី នួន ជា សួរសំណួរផ្សេងៗទៅសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលអនាគត ដែលផ្អែកលើឯកសារនានាដែលមេធាវីការពារក្តីធ្លាប់លាក់កំបាំងដោយចេតនា និងខកខានមិនបានជូនដំណឹងដល់អង្គជំនុំជម្រះ និងភាគីដទៃទៀត ស្របតាមវិធាន និងសេចក្តីសម្រេចនានារបស់តុលាការ។៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៥ | **លោក សេង លាង**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | |